យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា និង នាយកវិទ្យាល័យ
ព្រែកអញ្ចាញមាន ភារៈកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**តុល ឡោះ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

## ប្រកាស លេខ : ១១៦ អយក.ប្រក
## ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រឡងសញ្ញាបត្រ
## មធ្យមសិក្សាកំរិត ២

* * *

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី ១៩-១១-១៩៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ
- បានឃើញប្រកាសក្រសួងលេខ ២៣២៩ ចុះថ្ងៃទី ១៧.៥.១៩៨០ ស្តីពីការប្រលងសញ្ញាប័ត្រក៏រិតសិក្សាទី ៣

– យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និង កីឡា

**សំរេច**

**ប្រការ ១ :** មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ លើកទី១ និង លើកទី២ ត្រូវកំណត់ ដោយក្រសួងអប់រំ យុវជន និង កីឡា រៀងរាល់ឆ្នាំសិក្សា ។

**ប្រការ ២ :** ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និង នាយកគ្រឹះស្ថានសិក្សា ដែលគ្រឹះ ស្ថានត្រូវបានកំនត់ជាមណ្ឌលប្រលងមានភារៈ រៀបចំបន្ទប់ប្រលង សៀវភៅ រូបថតបេក្ខជន បញ្ជីផ្សេង ៗ និងសំភារៈ ចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រលង អោយហើយស្រេច មុន បើកសម័យប្រលង ។

– ចំពោះសាលាក្រោមឱវាទផ្ទាល់ នៃក្រសួងអប់រំ យុវជន និង កីឡា នាយកគ្រឹះស្ថានសិក្សា ក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យ សិក្សា ។

**ប្រការ ៣ :** នឹងអាចចុះឈ្មោះប្រលងលើកទី ១ បាន បេក្ខជនទាំងឡាយណាជាសិស្សថ្នាក់ទី ១១ នៃ វិទ្យាល័យសាធារណៈ និងឯកជនដែលបានរៀបចំកម្មវិធីសិក្សាថ្នាក់ទី១១ ។ ពាក្យសុំចុះ ឈ្មោះប្រលងមានបិទតែមប្រ៍ ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តាមឋានា នុក្រម ។

**ប្រការ ៤ :** និងអាចអនុញ្ញាតអោយចូលរួមប្រលងលើកទី ២ បាន ÷

. បេក្ខជនដែលប្រលងធ្លាក់លើកទី១ និងបានពិន្ទុសរុបនៃការប្រលង លើកទី១ ចាប់ ពី៣/៤ នៃពិន្ទុ២៥០ (គឺចាប់ពីពិន្ទុ១៨០)ឡើងទៅ ។

. បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី១ តែអាក់ខានពុំបានចូលរួមប្រលង ឬបានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមាន ជំងឺឬគ្រោះថ្នាក់ផ្សេងៗជាក់ស្តែង ហើយមានពាក្យសុំច្បាប់ត្រឹមត្រូវ ដោយ មានការបញ្ជាក់ពីឪពុកម្តាយ ឬ អាណាព្យាបាល ស្នើសុំទៅរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា តាមរយៈប្រធានមណ្ឌល ដែលសាមីខ្លួនត្រូវ ប្រលង ។

ប្រការ ៥ : អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ជាបេក្ខជនស្វ័យរិន បាន អតីតបេក្ខជនដែលបាន ប្រលងធ្លាក់ សញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។

ប្រការ ៦ : បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ

- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាកំរិត១ ១ សន្លឹក
- សលាកប័ត្រឯកត្តជនទំហំ ១៥ ស.ម គុណនឹង ២១ ស.ម មានបិទរូបថតថ្មី ថតចំពីមុខទំហំ ៤ ស.ម × ៦ ស.ម ចំនួន ៤ សន្លឹក
- បង្កាន់ដៃបង់សិទ្ធិប្រលង ១ ច្បាប់
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ ៤ ស.ម គុណ ៦ ស.ម «រូបដែលបានបិទលើ សលាកប័ត្រឯកត្តជន» ចំនួន ៣ សន្លឹក
- សៀវភៅសិក្ខាគារិក «ចំពោះសិស្សសាលាឯកជន»

ប្រការ ៧ : ពាក្យសុំចុះឈ្មោះប្រលងលើកទី ១ និងលើកទី ២ នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែល ខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សា ត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរ អប់រំ យុវជន និង កីឡា ខេត្ត - ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរទៅតាមបន្ទប់ប្រលង។

ប្រការ ៨ : បេក្ខជនដែលបានប្រកាសថាត្រូវបានប្រឡងលើកទី ២ មិនបាច់ដាក់ពាក្យប្រលងទៀតទេ ។ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង មានភារៈរៀបចំបែងចែកឈ្មោះបេក្ខជន តាម លំដាប់អក្សរទៅតាមបន្ទប់ប្រលង ។

ប្រការ ៩ : បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រលងលើកទី ១ ដោយមានបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ នៃសម័យប្រលងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត - ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន ឬនៅនាយកដ្ឋានចំនេះទូទៅនិងមធ្យមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ១០ :** មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត- ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅក្រសួងអប់រំ យុវជន និង កីឡា «នាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា» ដើម្បីពិនិត្យ និង សំរេច លើបេក្ខភាព ។

**ប្រការ ១១ :** ការក្លែងបន្លំផ្សេងៗ ពីសំណាក់បេក្ខជន ត្រូវទទួលការបញ្ឈប់មិនអនុញ្ញាតអោយប្រលង ចំនួនពីរឆ្នាំ ។

**ប្រការ ១២ :** មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និង សមាជិកគណៈមេប្រយោគមួយ ចំនួនតាមការចាំបាច់នៃមណ្ឌលប្រលង ។

**ប្រការ ១៣ :** សមាសភាព និង ចំនួនព្រមទាំងលិខិតឧទ្ទេសនាមគណៈមេប្រយោគត្រូវសំរេចដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ១៤ :** ចំនួនអនុរក្ស នៃមណ្ឌលប្រលង ត្រូវគិតតាមចំនួនបន្ទប់ប្រលង គុណនឹង ២,៥ ។

**ប្រការ ១៥ :** បន្ទប់ប្រលងនីមួយៗត្រូវដាក់បេក្ខជនត្រឹម ២៥ «ម្ភៃប្រាំ» នាក់ ។ បើមានបេក្ខជននៅសល់ពី ០៥ «ប្រាំ» នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

**ប្រការ ១៦ :** ប្រធានគណៈមេប្រយោគនៃមណ្ឌលនីមួយ ។ ជាអ្នកទទួលខុសត្រូវរួមក្នុងដំណើរ ការប្រព្រឹត្ត ទៅនៃការប្រលង ទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស ចំពោះក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ១៧ :** ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬធ្វើអន្តរាគមន៍ ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុងនៃមណ្ឌលប្រលង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

**ប្រការ ១៨ :** មណ្ឌល ឬ អនុមណ្ឌលប្រលងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រលងគណៈមេប្រយោគនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេ ប្រយោគ ទូទាំងប្រទេសដើម្បី នឹងដោះស្រាយ ឬ សុំការសំរេចពីក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ១៩ :** ប្រធានគណៈមេប្រយោគត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និង សមាជិកគណៈមេ ប្រយោគ អោយទទួលខុសត្រូវតាមមុខងាររៀង ៗ ខ្លួន ។

**ប្រការ ២០ :** ភារកិច្ចនៃគណៈកម្មការ អនុគណៈកម្មការ និង សមាជិក នៃគណៈមេប្រយោគ នឹង មានចែងក្នុងសេចក្ដីណែនាំមួយរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ ២១ :** ទៅពេលប្រលងបេក្ខជនទាំងឡាយ ត្រូវមកប្រលងអោយទាន់ពេលវេលាកំណត់ ។ ការមក ប្រលងយឺតយ៉ាវ លើសពី ១៥ នាទី មិនអនុញ្ញាតអោយចូលប្រលងឡើយ ។ នៅពេលចូលប្រលងបេក្ខជន ត្រូវមានលិខិតសំគាល់ខ្លួន មានបិទរូបថត និងមានបញ្ជាក់ច្បាស់លាស់ ។ ជនដែលគ្មានលិខិតសំគាល់ ខ្លួន មិនអនុញ្ញាតអោយចូលប្រលងឡើយ ។

**ប្រការ ២២ :** មិនអនុញ្ញាតអោយមានការប្រលងជំនួសគ្នាឡើយ ។

**ប្រការ ២៣ :** មិនអនុញ្ញាតអោយបេក្ខជនទាំងឡាយ យកឯកសារនានាជាប់នឹងខ្លួនចូលក្នុងបន្ទប់ប្រលងជាដាច់ ខាត ។

**ប្រការ ២៤ :** បេក្ខជនទាំងឡាយត្រូវអង្គុយតាមលេខតុ របស់ខ្លួនគ្រប់វិញ្ញាសា ។

**ប្រការ ២៥ :** បេក្ខជនទាំងឡាយ ត្រូវធ្វើវិញ្ញាសាលើក្រដាសប្រលង ដែលអនុរក្សចែកអោយ ។ បេក្ខជនមិនត្រូវធ្វើសញ្ញាអ្វី លើក្រដាសប្រលងដែលនាំអោយស្គាល់ថា ជាសន្លឹកកិច្ចការរបស់សាមីខ្លួន ជាដាច់ខាត ។ សន្លឹកកិច្ចការដែលមានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ ។

**ប្រការ ២៦ :** នៅពេលធ្វើវិញ្ញាសាប្រលងមិនអនុញ្ញាតអោយបេក្ខជនលួចចំលង ឬមានបំណងលួចចំលងជាដាច់ខាត ។ កំហុសនៃការលួចចំលង ឬបំណងលួចចំលង នឹងមានចែងក្នុងអត្ថបទមួយ ។

**ប្រការ ២៧** វិញ្ញាសា និង ថេរវេលានៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិ២ លើកទី១ និង លើកទី២ ត្រូវកំនត់ដូចតទៅ ÷

១– តែងសេចក្ដី រយៈពេល ៣ ម៉ោង

**ប្រការ ៣៩ :** នឹងត្រូវប្រកាសថាត្រូវបានប្រលងលើកទី២ បេក្ខជនទាំងឡាយណា ដែលមិនបានប្រកាស ថាប្រលងជាប់លើកទី១ហើយបាន ពិន្ទុសរុបចាប់ពី ១៥០ ឡើងទៅដោយមិនគិតពិន្ទុសូន្យ ចំពោះមុខវិជ្ជាណាមួយ ។

**ប្រការ ៤០ :** បទបញ្ញត្តិស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិ២ ពីមុន ៗ ទាំងឡាយណាដែល ផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤១ :** ប្រធានមន្ទីរ និង ប្រធាននាយកដ្ឋានចំនេះទូទៅ និង មធ្យមសិក្សា និង អង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន ដើម្បីអោយបានសំរេចនូវប្រកាសនេះ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**តុល ឡោះ**

* * *

## ៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

**ប្រកាស លេខ : ០៦៨ ស.ឧបឡ**

**ស្តីពីការកំណត់តួនាទី ភារកិច្ច របស់ភ្នាក់ងារ**

**ត្រួតពិនិត្យឱសថនៅតាមច្រកព្រំដែន**

* * *

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល